ភ្នំពេញ, ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៤

## លិខិតចំហរចំពោះគណបក្សប្រជាជនកម្ពុជា និង គណបក្សសង្គ្រោះជាតិ

សម្ព័ន្ធកំណែទម្រង់ការបោះឆ្នោតយល់ឃើញថា ដើម្បីឱ្យការអនុវត្តកិច្ចព្រមព្រៀងដំណោះស្រាយនយោបាយរវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ ប្រព្រឹត្តទៅប្រកបដោយភាពប្រាកដប្រជា និងតម្លាភាព ហើយអាចមើលឃើញពីភាពប្តេជ្ញានៃភាគីទាំងសងខាង សម្ព័ន្ធកំណែទម្រង់ការបោះឆ្នោតសូមផ្តល់អានុសាសន៍ដូចខាងក្រោមៈ

១. ការធ្វើវិសោធន៍កម្មនៃរដ្ឋធម្មនុញ្ញដាក់ស្ថាប័នរៀបចំការបោះឆ្នោតនៅក្នុងរដ្ឋធម្មនុញ្ញត្រូវតែមានចែងលម្អិត និងឱ្យបានច្បាស់ អំពីសិទ្ធិអំណាច ការទទួលខុសត្រូវ ភាពឯករាជ្យរបស់ស្ថាប័ននេះ ហើយអនុវត្តសមត្ថកិច្ចរបស់ខ្លួនដោយតម្លាភាព និងមានការចូលរួមពីភាគីពាក់ព័ន្ធ។ ស្ថាប័ននេះត្រូវមានស្វយ័តភាពនៃកញ្ចប់ថវិកា ហើយការចំណាយត្រូវតែមានតម្លាភាព។ រាល់ការងាររបស់ស្ថាប័នរៀបចំការបោះឆ្នោត ត្រូវបង្ហាញជូនសាធារណៈជន និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់ក្នុងការចូលរួមតាមដាន ឬ/និងធ្វើសវនកម្មទៅលើការងារ និងទិន្នន័យសំខាន់ៗរបស់ស្ថាប័ននេះ។ ស្ថាប័ននេះត្រូវតែជាស្ថាប័នតែមួយ ដែលទទួលខុសត្រូវធ្វើការចុះឈ្មោះអ្នកបោះឆ្នោត ឬ/និងធ្វើបញ្ជីឈ្មោះបោះឆ្នោត និងមានសិទ្ធិគ្រប់គ្រាន់ក្នុងការបង្កើតគណៈកម្មការផ្សេងៗទៀតដើម្បីប្រសិទ្ធិភាពនៃការងាររបស់ស្ថាប័ននេះរួមទាំង ការបង្កើតយន្តការដាច់ដោយឡែកដោះស្រាយវិវាទបោះឆ្នោត និងត្រួតពិនិត្យប្រព័ន្ធផ្សព្វផ្សាយអំឡុងពេលបោះឆ្នោត។

នៅក្នុងអំឡុងពេលបោះឆ្នោតស្ថាប័ននេះមានសិទ្ធិ អំណាចក្នុងការចេញបទបញ្ជាហាមឃាត់ ឬលប់ចោលសេចក្តីសំរេច ឬផ្អាកសកម្មភាពទាំងឡាយណា ដែលប៉ះពាល់ដល់ដំណើរការបោះឆ្នោត

ដោយសេរី និងយុត្តិធម៌។ បទបញ្ញាទាំងឡាយរបស់ស្ថាប័ននេះត្រូវបានអនុវត្តដោយអាជ្ញាធរ និងស្ថាប័នមានសមត្ថកិច្ចនានារបស់រាជរដ្ឋាភិបាលប្រកបដោយប្រសិទ្ធិភាព។

បេក្ខជនសម្រាប់ជាសមាជិកស្ថាប័ននេះ ត្រូវជាបុរស និងស្ត្រីដែលមានលក្ខណៈសម្បត្តិសំខាន់ដែល**មិនមែនជាសហព័ទ្ធ ឬសាច់ញាតិបង្កើត**របស់ថ្នាក់ដឹកគណបក្សដែលមានអាសនៈក្នុងរដ្ឋសភា រួមទាំងមានការសន្យាមិនជាសមាជិកនៃគណបក្សនយោបាយណាមួយឡើយក្នុងរយៈពេលពីរឆ្នាំ គិតពីថ្ងៃចប់អាណត្តិ។

សមាជិកស្ថាប័ននេះត្រូវមានអភ័យឯកសិទ្ធិ និងត្រូវបានធានាមិនឱ្យមានការផ្លាស់ប្តូរក្នុងអាណត្តិលើកលែងតែៈ

- សាមីខ្លួនទទួលមរណភាព។
- សាមីខ្លួនសុំលាឈប់ជាលាយលក្ខណ៍អក្សរ។
- សាមីខ្លួនបាត់បង់សម្បទាវិជ្ជាជីវៈ។

២. គណៈកម្មការចំរុះ និងក្រុមការងារទាំងបីដែលមានសមាសភាពពីគណបក្សនយោបាយទាំងពីរត្រូវធ្វើការ ដោយអនុលោមទៅតាមគោលការណ៍បើកចំហរ និងតម្លាភាពដែលអនុញ្ញាតឱ្យអង្គការសង្គមស៊ីវិល ឬ/និងអ្នកពាក់ព័ន្ធនានាពីមជ្ឈដ្ឋានជាតិ និងអន្តរជាតិចូលរួមផ្តល់យោបល់ ឬ/និងសង្កេតនៅក្នុងកិច្ចប្រជុំពិភាក្សា។

៣.រដ្ឋសភាដែលមានការចូលរួមពីគណបក្សប្រជាជនកម្ពុជានិងគណបក្សសង្គ្រោះជាតិគួរចាប់ផ្តើមកិច្ចការរបស់ខ្លួននៅពេលដែលគណៈកម្មការចំរុះដែលមានសមាសភាពពីគណបក្សនយោបាយទាំងពីរបានធ្វើការងារចប់សព្វគ្រប់ទៅលើសេចក្តីស្នើនៃវិសោធនកម្ម រដ្ឋធម្មនុញ្ញ និងច្បាប់នានាដែលពាក់ព័ន្ធរួចអស់ហើយ។ រដ្ឋសភាគួរពន្លឿននូវការអនុម័តនូវក្របខណ្ឌច្បាប់ដែលគណៈកម្មការចម្រុះដាក់ជូនឱ្យបានចប់សព្វគ្រប់នៅក្នុងខែកញ្ញា ឆ្នាំ២០១៤។

# សម្ព័ន្ធកំណែទម្រង់ការបោះឆ្នោត

The Electoral Reform Alliance (ERA)

សម្ព័ន្ធកំណែទម្រង់ការបោះឆ្នោតបានរៀបចំសេចក្តីស្នើវិសោធនកម្មរដ្ឋធម្មនុញ្ញ និងច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ហើយត្រៀមផ្តល់ និងបកស្រាយសេចក្តីស្នើទាំងនេះ បើសិនមានការស្នើសុំពីគណៈកម្មការចម្រុះ ឬក្រុមការងារនៃគណបក្សនយោបាយទាំងពីរ។

សម្រាប់ព័ត៌មានបន្ថែម៖

| ឈ្មោះ | អង្គការ | លេខទូរស័ព្ទ |
|---|---|---|
| • លោក នី ចរិយា | អាដហុក | ០១១២៧៤៩៥៩ |
| • អ្នកស្រី រស់ សុភាព | ហ្គាដស៊ី | ០១៦៨៨១២៥០ |
| • លោក ព្រាប កុល | តម្លាភាពកម្ពុជា | ០១២៨៧៧៨៣៣ |
| • លោក ហង្ស ពុទ្ធា | និចហ្វិច | ០១២៩៥៩៦៦៦ |
| • លោក យង់ គិមអេង | ភីឌីភី សិនធ័រ | ០១៦៨២៨២១១ |
| • លោក គល់ បញ្ញា | ខុមហ្វ្រែល | ០១២៩៤២០១៧ |
| • លោក សុខ ពិទូរ្យ | វាយ ស៊ី ស៊ី | ០១៧២៧៣៣០៣ |
| • លោក គាន ពន្លក | ជ្រោក | ០១២៥៥១៤៦៦ |
| • លោក ហុង គីមសួន | សម្ព័ន្ធស៊ីសា | ០១២៩៤៥៥០៥ |
| • លោក ប៉ា ងួនទៀង | ស៊ី ស៊ី អាយ អឹម | ០៦០៤០៩៩ ៩៩ |
| • លោក យ៉េង វិរៈ | ខ្លែក | ០១២៨០១២៣៥ |